**គណៈកម្មាធិការដើម្បីការបោះឆ្នោតដោយសេរី និងយុត្តិធម៌នៅកម្ពុជា (គ.ប.ស.យ)**

Committee For Free And Fair Elections In Cambodia (COMFREL)

ទីស្នាក់ការកណ្ដាល ផ្ទះលេខ ១៣៨ ផ្លូវ ១២២ សង្កាត់ទឹកល្អក់ ១ ខណ្ឌទួលគោក រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា

Central Office: #138, St. 122, Teuk Laak I, Tuol Kork, Phnom Penh, CAMBODIA.

ខុមហ្វ្រែល COMFREL

P.O. Box 1145, Tel: (855) 23 884 150/12 942 019, Fax: (855) 23 883 750 E-mail: comfrel@online.com.kh, comfrel@comfrel.org or comfreladmin@online.com.kh, Site : www.comfrel.org

**គណៈកម្មាធិការនាយក**
BOARD OF DIRECTORS

លោក **ធន សារាយ**
Mr. THUN SARAY
ប្រធានគណៈកម្មាធិការនាយក
និងជាប្រធាន ADHOC

លោក **សុក សំអឿន**
Mr. SOK Sam Oeun
អនុប្រធានគណៈកម្មាធិការនាយក
និងជានាយក CDP

លោក **យឹម ប៉ូ**
Mr. YIM Po អគ្គហេរញ្ញិក
និង នាយក CCPCR

កញ្ញា **ស៊ុន ចាន់សែន**
Miss. SUN Chansen
ប្រធាន KYA

លោក **មុំ សារិន**
Mr. MOM Sarin
នាយក HRCDO

លោកស្រី **ពឹង យក់ហៀប**
Mr. PEUNG Yok Hiep
នាយិកា LAC

លោកស្រី **ទីវ សារាយេត**
Ms. TIV Sarayet
សហនាយិកា WMC

កញ្ញា **សយ សារា វឌ្ឍនី**
Miss. SAY Sara Vathany
នាយិកា CWCC

លោក **គឹម សុវណ្ណ**
Mr. KIM Sovann
នាយក VIGILANCE

លោក **អាង ច័ន្ទឫទ្ធិ**
Mr. ANG Chanrith
នាយក KKKHRO

លោក **យង់ គិមអេង**
Mr. YONG Kim Eng
នាយក PDP-Center

លោក **ភួង សិទ្ធិ**
Mr. PHUONG Sith

លោក **សឺន សែត**
Mr. SEN Set

ស.ប្រ.ក.៣/លេខ ០៥/០៩ គ.ប.ស.យ/អ.ក

# សេចក្ដីប្រកាសព័ត៌មាន

## ស្ដីពី

## របាយការណ៍លទ្ធផលសិក្ខាសាលាម្ចាស់ឆ្នោត

## ក្នុងការកំណត់លក្ខខណ្ឌសន្ទស្សន៍[១] នៃវិស័យអាទិភាពក្នុងខេត្ត កោះកុង

*ភ្នំពេញ, ថ្ងៃទី ២៦ ឧសភា ២០០៩*

ម្ចាស់ឆ្នោតប្រមាណ ៨០នាក់ ដែលតំណាងឱ្យសហគមន៍នេសាទ ព្រៃឈើ ដីធ្លី ... សមាគម និងអង្គការមិនមែនរដ្ឋាភិបាលនានា អាជីវករ/ពាណិជ្ជករ មន្ត្រីរាជការ សិស្ស/ និស្សិត កសិករ ដែលមកពីស្រុកស្មាច់មានជ័យ ស្រុកមណ្ឌលសីមា ស្រុកថ្មបាំង ស្រុកបូទុមសាគរ និងក្រុងខេមរភូមិន្ទ ក្នុងខេត្តកោះកុងបានធ្វើការកំណត់លក្ខខណ្ឌសន្ទស្សន៍នៃវិស័យអាទិភាពនៅក្នុងសិក្ខាសាលានៅខេត្តកោះកុង។ នៅក្នុងសិក្ខាសាលានេះ ដែលមានសិក្ខាកាមស្ត្រីចូលរួមប្រមាណ ២០% បានធ្វើការកំណត់ និងជ្រើសរើសលក្ខខណ្ឌសន្ទស្សន៍នៃវិស័យអាទិភាព ១០ សម្រាប់ខេត្ត កោះកុង។ អភិបាលរងខេត្តកោះកុង ឯកឧត្តម **សាយ សុជាតិ** បានថ្លែងបើកសិក្ខាសាលាថា សិក្ខាកាមចូលរួមទាំងអស់ នឹងអាចកំណត់លក្ខខណ្ឌសន្ទស្សន៍បានដើម្បីបំពេញនូវចំណុចខ្វះខាតមួយចំនួនក្នុងខេត្ត។

លក្ខខណ្ឌសន្ទស្សន៍នៃវិស័យអាទិភាពទាំង១០ ដែលបានកំណត់ដោយម្ចាស់ឆ្នោតក្នុងខេត្តកោះកុងរួមមាន:

| **លក្ខខណ្ឌសន្ទស្សន៍នៃវិស័យអាទិភាពទាំងដប់នៅក្នុងខេត្ត កោះកុង** |
|---|
| ១) សុំផ្លូវ (មានដាក់ស្ពាន និងបណ្ដាញលូ) ក្រាលគ្រួសក្រហម ចុះពីផ្លូវជាតិលេខ៤៨ ដល់ស្រុកថ្មបាំងប្រវែង ៣៥ គ.ម ទទឹង ១២ ម នៅស្រុកថ្មបាំង និងជួសជុលផ្លូវ លូ និងស្ពាន ពី ចាំយាម ទៅតំបន់ វង់កថាក់ (ស្ថិតនៅឃុំ ប៉ាក់ខ្លង ស្រុកមណ្ឌលសីមា) ចំនួន ៦គ.ម ធ្វើអោយហើយក្នុងឆ្នាំ ២០១១។ |
| ២) ចែកដីសម្បទានសង្គមកិច្ចជូនគ្រួសារដែលគ្មានដីកសិកម្មចាប់ ពីឆ្នាំ២០០៩ នៅទូទាំង ៧ស្រុកក្នុងខេត្តកោះកុង។ |
| ៣) សុំអោយសមត្ថកិច្ច (ប៉ូលីស ប៉េអឹម) រួមសហការលុបបំបាត់ចរាចរគ្រឿងញៀនទាំងស្រុង នៅក្នុងខេត្តកោះកុង មុនឆ្នាំ២០១១ ។ |

---

[១] ការសន្យាណាដែលមានសូចនាករច្បាស់លាស់-អាចមានជាក់ស្ដែង អាចវាស់បានដូចជាការអនុម័តច្បាប់ ការបង្កើតស្ថាប័ន ឬជាសកម្មភាព ការអនុវត្តអ្វីមួយច្បាស់លាស់ ដោយមានគោលដៅ ពេលវេលា ឬមានចំនួនកំណត់ច្បាស់លាស់ ឬមួយប្រៀបធៀបទៅនឹងអត្រាណាមួយច្បាស់លាស់។

| |
|---|
| ៤) បញ្ចុះតម្លៃ ៤០ភាគរយ នៃតំលៃសេវាព្យាបាលបច្ចុប្បន្នតាមមន្ទីរពេទ្យ មណ្ឌលសុខភាព និងប៉ុស្តិ៍សុខភាពនៅទូទាំងខេត្ត ចាប់ពីចុងឆ្នាំ ២០០៩។ |
| ៥) សុំការបណ្តុះបណ្តាលបច្ចេកទេសដាំដំណាំ ដូចជាដំណាំស្រូវ និងដំណាំហូបផ្លែ (ធូរេន សាវម៉ាវ និងកៅស៊ូ) និងផ្តល់ពូជដើម្បីដាំដំណាំ ជាពិសេសសុំអោយរដ្ឋាភិបាលជួយរកទីផ្សារដើម្បីលក់ផលិតផលទាំងនេះអោយបានចន្លោះឆ្នាំ ២០០៩-២០១០ នៅស្រុកបូទុមសាគរ ស្រែអំបិល ថ្មបាំង និងកោះកុង ។ |
| ៦) ជំរុញតំបន់សេដ្ឋកិច្ចពិសេសចាំយាម អោយមានដំណើរការនៅក្នុងឆ្នាំ ២០១១។ |
| ៧) សុំបុគ្គលិកពេទ្យយកចិត្តទុកដាក់ចំពោះអ្នកជម្ងឺក្រីក្រ (មានសីលធម៌វិជ្ជាជីវៈដោយព្យាបាលអ្នកជំងឺភ្លាមៗពេលទៅដល់មន្ទីរពេទ្យដោយមិនគិតពីថ្លៃព្យាបាល) តាមមន្ទីរពេទ្យ មណ្ឌលសុខភាព និងប៉ុស្តិ៍សុខភាព នៅទូទាំងខេត្ត ចាប់ពីចុងឆ្នាំ ២០០៩។ |
| ៨) សុំលូទឹកសងខាងផ្លូវលេខ៤៨ ដែលមានមុខកាត់ ៨ តឹក (០.៨ ម) ចាប់ពីសាលាស្រុកមណ្ឌលសីមា ដល់មាត់សមុទ្រ ត្រូវធ្វើអោយហើយក្នុងឆ្នាំ ២០១២។ |
| ៩) សុំការបណ្តុះបណ្តាលបច្ចេកទេស និងពូជក្នុងការចិញ្ចឹមសត្វ (គោ ជ្រូក មាន់ ត្រី សត្វសមុទ្រ) តាមសហគមន៍ និងគ្រួសារ និងសុំផ្តល់ថ្នាំបង្ការក្នុងការចិញ្ចឹមសត្វជារៀងរាល់ឆ្នាំ ចាប់ពីឆ្នាំ២០០៩ នៅក្នុងស្រុកទាំង ៧។ |
| ១០) បង្កើនប្រាក់បៀវត្សរ៍ឱ្យដល់គ្រូបឋមសិក្សាដែលរស់នៅតាមសហគមន៍ក្នុងខេត្ត អោយបានច្រើនជាងសែសិបម៉ឺនរៀលនៅឆ្នាំ ២០១២ទៅ |

សិក្ខាសាលានេះត្រូវបានរៀបចំឡើងដោយ គណៈកម្មាធិការខុមហ្វ្រែល ដោយមានកិច្ចសហការជាមួយអង្គការសង្គ្រោះសត្វព្រៃកម្ពុជា (SCW) អង្គការម៉ារីស្តុប (MARIE STOPES)។ សិក្ខាសាលានេះ ជាគំនិតបង្កើតថ្មីមួយក្នុងគោលបំណងឱ្យប្រជាពលរដ្ឋ ដែលជាម្ចាស់ឆ្នោតនៅតាមមណ្ឌលនីមួយៗ:

១) មានការយល់ដឹងពីកម្មវិធីនយោបាយ និងយុទ្ធសាស្ត្រចតុកោណរបស់រាជរដ្ឋាភិបាលជាប់ឆ្នោតឆ្នាំ ២០០៨

២) ចូលរួមក្នុងការកំណត់លក្ខខណ្ឌសន្ទស្សន៍នៃវិស័យអាទិភាពនានា ដែលត្រូវការចាំបាច់ក្នុងមណ្ឌល (ខេត្ត) របស់ខ្លួន

៣) និង លក្ខខណ្ឌសន្ទស្សន៍នៃវិស័យអាទិភាពនានាសម្រាប់មណ្ឌលនីមួយៗ ត្រូវបានចងក្រងជារបាយការណ៍ ដែលអាចឱ្យសិក្ខាកាមងាយចងចាំដើម្បីចូលរួមតាមដាន និងជម្រុញការអនុវត្តរបស់រាជរដ្ឋាភិបាល អ្នកតំណាងរាស្ត្រ ក្រុមប្រឹក្សា/គណៈអភិបាលខេត្ត-រាជធានី ក្នុងការសម្រេចបានលក្ខខណ្ឌសន្ទស្សន៍នៃវិស័យទាំងនោះ។

*សម្រាប់ព័ត៌មានបន្ថែមៗសូមទាក់ទង:*


- លោក **គីម ឈន** អ្នកសម្របសម្រួលជាន់ខ្ពស់នៃកម្មវិធីខុមហ្វ្រែល ទូរស័ព្ទ: ០១២ ៩៤២ ០១៩
- លោក **សុខ ពិទូរ្យ** អ្នកសម្របសម្រួលស្តីទីផ្នែកអង្កេតខុមហ្វ្រែល ទូរស័ព្ទ: ០៨៩ ៥២៥ ៤៤៦